មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

**បទចចារណកថា ម.ស.ម.ក.**

ភ្នំពេញ ថ្ងៃទី ៣ ខែមករា ឆ្នាំ២០១៣

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាសារទរ ចំពោះ

## សាលក្រមសាលាឧទ្ធរណ៍លើកលែងទោស ផ្លុង ស្រីរ៉ាន់

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា (ម.ស.ម.ក.) សារទរទ្រសេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍កាលពីថ្ងៃទី ៣១ ខែធ្នូ ឆ្នាំ២០១២ ដែលបានបដិសេធសាលក្រមសាលាដំបូងរាជធានីភ្នំពេញជុំវិញ កាត់ទោស ផ្លុង ស្រីរ៉ាន់។ កញ្ញា ស្រីរ៉ាន់ ដែលជាអ្នកស្រឡាញ់ភេទដូចគ្នា ត្រូវបានចោទប្រកាន់ថាបានបង្ខាំងនិងជួញដូរមនុស្សខុសច្បាប់ ដោយគ្រួសារមិត្តស្រីរបស់នាង ហើយនាងត្រូវបានកាត់ទោសឲ្យជាប់ពន្ធនាគាររយៈពេល៥ឆ្នាំ កាលពីខែវិច្ឆិកា ឆ្នាំ ២០១១ ពីបទរួមភេទជាមួយអនីតិជន។ ក៏ប៉ុន្តែ ការកាត់ទោសនេះជាទូទៅត្រូវបានគេជឿថា ឯកសារដែលបានផ្តល់ដោយគ្រួសារដើមបណ្តឹងដែលថាក្មេងស្រីនោះមានអាយុ១៤ឆ្នាំគឺជាការក្លែងបន្លំ និងដាក់ការចោទប្រកាន់មួយពីព្រោះពួកគាត់ជំទាស់នឹងកូនស្រីរបស់ខ្លួនដែលមានទំនាក់ទំនងភេទដូចគ្នា។ សាលាឧទ្ធរណ៍បានបដិសេធសាលក្រមនេះដោយសំអាងថាពុំមានឯកសារគ្រប់គ្រាន់ដែលបញ្ជាក់ថាក្មេងស្រីនោះជាអនីតិជន។

សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍ដែលបដិសេធសាលក្រមទោសនេះ គឺជាសញ្ញាវិជ្ជមាន ហើយបង្ហាញថាតុលាការកម្ពុជាគឺមិនលម្អៀងនិងឯករាជ្យ។ លើសពីនេះទៀត ករណីនេះគួសបញ្ជាក់ថា នេះជាលើកទីមួយដែលតុលាការកម្ពុជាបានទទួលស្គាល់ការទំនាក់ទំនងភេទដូចគ្នា។ ម.ស.ម.ក. សង្ឃឹមថាករណីនេះនឹងនាំអោយមានការកើនឡើងនូវការទទួលស្គាល់ជាសាធារណៈទៅលើសហគមន៍ស្ត្រីស្រឡាញ់ស្ត្រី បុរសស្រឡាញ់បុរស អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទនៅកម្ពុជាហើយនិងកាត់បន្ថយការរើសអើងទៅលើពួកគាត់នៅគ្រប់វិស័យនៃសង្គមកម្ពុជា។

**អ្នកសម្របសម្រួលគំពោងមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា លោក ថេង ណាន អធិប្បាយថា៖**

“សេចក្តីសម្រេចរបស់សាលាឧទ្ធរណ៍គឺជាសញ្ញាវិជ្ជមានសម្រាប់ប្រព័ន្ធតុលាការកម្ពុជា និងសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទនៅកម្ពុជា។ ខ្ញុំសង្ឃឹមថាការសម្រេចនេះនឹងបញ្ជូនសារដ៏រឹងមាំមួយដល់ដៃគូដែលស្រឡាញ់ភេទដូចគ្នានៅកម្ពុជាដែលគួរតែត្រូវបានទទួលការទទួលស្គាល់ ហើយសង្ឃឹមថាប្រព័ន្ធតុលាការកម្ពុជានឹងមិនបន្តអោយមានការរើសអើងទៅលើសហគមន៍អ្នកស្រឡាញ់ភេទដូចគ្នា អ្នកស្រឡាញ់ទាំងពីរភេទ និងអ្នកប្តូរភេទនៅកម្ពុជាទៀតឡើយ។”

**សម្រាប់ព័ត៌មានបន្ថែមសូមទំនាក់ទំនងលោកចេងណានតាមរយៈទូរស័ព្ទ+៨៥៥(០)១២ ៤៨ ៨៨ ៩៨ឬផ្ញើអ៊ីម៉ែលមកកាន់**chamnan@cchrcambodia.org **ឬ កញ្ញា ហ្សូលីយ៉ែតរ៉ូស្សែឡូត ជាអ្នកប្រឹក្សា ម.ស.ម.ក តាមរយៈទូរស័ព្ទ+៨៥៥(០) ១៥ ៣៥ ០៦ ២០ឬ អ៊ីម៉ែលមកកាន់**julietterousselot@cchrcambodia.org

<u>បណ្ណាធិការ</u>

ម.ស.ម.កត្រូវបានបង្កើតឡើងនៅក្នុងខែវិច្ឆិកាឆ្នាំ២០០២ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ និងមិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់និងការពារលទ្ធិប្រជាធិបតេយ្យនិងការគោរពសិទ្ធិមនុស្សជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយនៅកម្ពុជា។

ម.ស.ម.កគឺជាសមាជិករបស់ដៃគូអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (អ៊ីហ្វិក) ដែលជាបណ្តាញសកលក្នុងការបញ្ចេញមតិដោយសេរី។

គេហទំព័រស្តីពីសិទ្ធិមនុស្សកម្ពុជាwww.sithi.orgទទួលបានរង្វាន់ប្រចាំឆ្នាំ២០១១របស់មូលនិធិនៃការបង្កើតថ្មីសម្រាប់សង្គមព័ត៌មានវិទ្យាក្នុងចំណាត់ថ្នាក់នៃសិទ្ធិនិងសេរីភាព។